**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សារលិខិតអបអរសាទរ

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងបំផុត ក្នុងឱកាសដែល **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ត្រូវបានជ្រើសរើសក្នុងការទទួលបាននូវពានរង្វាន់សន្តិភាពស៊ុនហាក់ ឆ្នាំ២០២២ ពីមូលនិធិស៊ុនហាក់។ នេះជាសក្ខីភាពបញ្ជាក់យ៉ាងប្រត្យក្សថា **សម្តេចតេជោ** ពិតជាកុលបុត្រខ្មែរដឹកនាំប្រទេសដ៏ឆ្នើមមួយរូបក្នុងការកសាងស្ថិរភាព ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជា ព្រមទាំងការនាំមកនូវសន្តិភាពនៅកម្ពុជា និងការលើកកម្ពស់សន្តិភាពនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដ៏ទូលំទូលាយ ប្រកបដោយភាពប៉ិនប្រសប់ និងមានគុណធម៌ក្នុងការដឹកនាំប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ និងមានកិត្តិនាមល្បីរន្ទឺនៅលើឆាកអន្តរជាតិ ជាពិសេសការចូលរួមចំណែកដ៏សំខាន់ក្នុងដំណោះស្រាយបញ្ហានានាទាំងនៅក្នុងក្របខ័ណ្ឌតំបន់ និងសកលលោក។

ក្នុងឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ ស្ញប់ស្ញែងព្រមទាំងសេចក្តីគោរពដឹងគុណដ៏ស្មោះ និងជារៀងរហូតចំពោះគំរូវីរភាពពោរពេញដោយមោទនភាពរបស់ **សម្តេចតេជោ** ដែលបានបំពេញបេសកកម្មជាប្រវត្តិសាស្ត្រប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ ក្នុងការរំដោះប្រទេសពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ការបង្រួបបង្រួម ផ្សះផ្សាជាតិ ការធ្វើឱ្យមានសុខសន្តិភាពពាសពេញប្រទេស និងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនជាលំដាប់រហូតមកទល់សព្វថ្ងៃ។រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** បានធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាកំពុងបន្តទទួលបាននូវការអភិវឌ្ឍថ្មីៗ ក្រោមសុខដុមរមនាភាពនៃសុខសន្តិភាព អធិបតេយ្យភាព ឯកភាពជាតិ បូរណភាពទឹកដី និងស្ថិរភាពជាតិដ៏រឹងមាំ ជាពិសេសមុខមាត់របស់កម្ពុជានៅលើឆាកអន្តរជាតិ។

ក្នុងឱកាសប្រកបដោយកិត្តិយស និងមោទនភាពជាតិនេះ យើងខ្ញុំសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិ ទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **សម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងគារវកិច្ចខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ ចន្ទ ១៤ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh